មជ្ឈមណ្ឌលឯកសារកម្ពុជា

# ទិដ្ឋភាពតូចមួយនៃឥទ្ធិពលការទំលាក់គ្រាប់បែករបស់អាមេរិកកាំង និងលទ្ធភាពក្នុងការស្វែងរកអដ្ឋិធាតុនៃជនជាតិអាមេរិកកាំងនៅក្នុងជុំរំ៨៤ របស់វៀតណាមដែលមានទីតាំងនៅក្នុងខេត្តរតនះគីរី

ថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០០០

ដោយ សួ ប៊ុនស៊ូ

ខេត្តតរនះគីរីជាពិសេសស្រុកតាវែងគឺជាស្រុកមួយដែលត្រូវបានញាំញីដោយការទំលាក់គ្រាប់បែករបស់ទាហានអាមេរិកកាំងក្នុងអំឡុងឆ្នាំ១៩៦៥-៧១ ។ ស្រុកនេះជាតិតាំងនិងជាដើមកំណើតនៃកំលាំងយោធារបស់ចលនាតស៊ូពួកខ្មែរក្រហម ។ ប្រជាប្រិយភាពរបស់ពួកខ្មែរក្រហមគឺកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ដោយសារតែការទំលាក់គ្រាប់បែករបស់ពួកចក្រពត្តិអាមេរិកនិងការឃុបឃិតរបស់បរិវារដែលជារដ្ឋាភិបាលគ្រប់គ្រងអំណាចនាឆ្នាំ១៩៧០-៧៥ ដែលដឹកនាំដោយឧត្តមសេនីយ៍ លុន ណុល ។

បើតាមសំដីរបស់លោក **ខាំ ឡឿន** អភិបាលខេត្តរតនគីរី ដែលមានស្រុកកំណើតនៅភូមិបានពង ឃុំវឺនសៃ ស្រុកវឺនសៃ ខេត្តរតនគីរីបានឲ្យដឹងថាក្នុងអំឡុង៨ឆ្នាំនៃការទំលាក់គ្រាប់បែករបស់ទាហានអាមេរិកកាំងនោះ ប្រជាជនជាច្រើនត្រូវរងនូវផលប៉ះពាល់យ៉ាំងខ្លាំងដោយសារអំបែងគ្រាប់និងជាតិថ្នាំពុលពណ៌លឿង ។ ក្នុងការហូបចុកម្តងៗអ្នកស្រុកភូមិទាំងអស់ត្រូវតែស្រុះចានក្បានដើម្បីជៀសវាង ឬបន្ថយការពុល ហើយឆ្នាំដែលមានការទំលាក់គ្រាប់ច្រើនជាងគេគឺចាប់ពីឆ្នាំ១៩៦៨ដល់ឆ្នាំ១៩៧១ ។ លោកបានបញ្ជាក់ទៀតថា រណ្តៅគ្រាប់ច្រើនរាប់មិនអស់នៅតែរក្សាទ្រង់ទ្រាយរបស់វានៅឡើយទេមកដល់សព្វថ្ងៃនេះ ។

ដោយទ្រាំមិនបាននូវទិដ្ឋភាពសោកនាដកម្មបែបនេះ ប្រជាជនភាគច្រើនក៏សំរេចចិត្តរត់ចូលព្រៃបង្កើតជាចលនាតស៊ូស្របពេលដែលពួកមេដឹកនាំខ្មែរធំៗមាន ប៉ុល ពត អៀងសារី ខៀវសំផន, សុន សេន ហៅតាខៀវ ឬ តាវ៉ែនតា និងអ្នកជំនិតៗជាច្រើនទៀតធ្វើការឃោសនាអូសទាញឲ្យចូលចលនាតស៊ូរបស់ខ្លួន ។ លោកផ្ទាល់ក៏បានចូលរួមចលនានេះដែរគឺនៅឆ្នាំ១៩៧០នៅភូមិតាវែងឃុំតាវែងស្រុកតាវែងខេត្តរតនគីរី ។ ហើយនៅក្នុងពេលនោះតំបន់

Documentation Center of Cambodia
Searching for the Truth
ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌
DC-Cam ◆ 66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
Tel: (855-23) 211-875 ◆ Fax: (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

តាវែងនេះទាំងមូលត្រូវបានកាត់ផ្តាច់ពីការគ្រប់គ្រងពីរដ្ឋាភិបាល **លុនណុល** ដែលគាំទ្រដោយសហរដ្ឋអាមេរិក ។

នៅថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ១៩៩៩ ក្រុមដែនទីមួយក្រុមដែលដឹកនាំដោយលោក សួ ប៊ុនស៊ួ ទទួលបន្ទុកសំគាល់ទីតាំងសំលាប់របស់ខ្មែរក្រហមដោយប្រើម៉ាស៊ីន ជី ភី អេស, ប្រមូលទិន្នន័យទាក់ទងនឹងសោកនាដកម្មដ៏ខ្លោចផ្សានៅក្នុងរបបនោះ ដោយស្វែងរកជួបជនរងគ្រោះដែលធ្លាប់ត្រូវបានខ្មែរក្រហមចាប់ដាក់គុក ធ្វើទារុណកម្ម ឬ អ្នកដែលអាចសើរើនូវសុបិន្តដ៏អាក្រក់របស់ខ្លួន ក្នុងសម័យខ្មែរក្រហម រួមជាមួយអ្នកសិក្សាស្រាវជ្រាវមួយរូបគឺលោកទៀង សុភៈវិជ្ជា នៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅធ្វើការសិកសាស្រាវជ្រាវរបស់ខ្លួននៅក្នុងខេត្តរតនៈគិរី ។ ថ្ងៃនោះគឺជាថ្ងៃទី ៦ នៃការស្រាវជ្រាវនៅក្នុងខេត្តនេះ ហើយក៏ជាថ្ងៃចុងក្រោយនៃគំរោងការសំភាសន៍នៅស្រុកមួយ ក្នុងចំណោមស្រុកនានាដែលជាគោលដៅរបស់ក្រុមស្រាវជ្រាវ ពោលគឺស្រុកតាវែង ។ យើងបានទៅដល់ទីស្នាក់ការស្រុកតាវែងនៅម៉ោង ១០: ២០ នាទីព្រឹក ។ នៅទីនោះយើងបានជួបជាមួយលោកអភិបាលស្រុក នុង ខាំ សឿន, អភិបាលរងទី ៣, លោក យ៉េង ខួង ព្រមទាំងមន្ត្រីការិយាល័យមួយចំនួនទៀត ។ គោលបំណងចំបងរបស់យើងគឺធ្វើការសម្ភាសន៍ជាមួយជនជាតិភាគតិចរបស់ខ្មែរដែលធ្លាប់បានធ្វើចលនាត៦ស៊ូប្រឆាំងនឹងចក្រពត្តិអាមេរិក ហើយក្រោយមកប្រឆាំងនឹងពួកខ្មែរក្រហមដែលសំលាប់និងគ្មានការទុកចិត្ត ចំពោះពួកខ្លួន ។ ហើយគោលបំណងមួយផ្សេងទៀតគឺស្វែងរកទីតាំងពិឃាតរបស់ខ្មែរក្រហម ។ ពេលនោះយើងបានទទួលពត៌មានមួយដែលទាក់ទងនឹងជំរុំរបស់វៀតណាមដែលសាងសង់ឡើងប្រហែលជាជាង ៣០ ឆ្នាំកន្លងមកហើយនោះ ។

នៅតាមបណ្តោយព្រំប្រទល់ខេត្តរតនគិរី ដែលមានចំងាយ ១០ គីឡូម៉ែត្រខាងកើតព្រំប្រទល់ប្រទេសវៀតណាមនោះជំរុំយោធាដ៏ធំមួយ ដែលជាចំនុចក្តៅនៃការទំលាក់គ្រាប់បែករបស់អាមេរិកកាំង ។ តំបន់នោះស្ថិតនៅក្នុងស្រុកតាវែង ខេត្តរតនៈគិរី ។ បើតាមសំដីរបស់លោក **យ៉េង ខួង** អាយុ ៤៨ ឆ្នាំ ជនជាតិព្រៅ ដែលបច្ចុប្បន្នជាទាហានស្រុកតាវែងខេត្តរតនគិរីបានឲ្យដឹងថាជំរុំនេះមានឈ្មោះថា **ជុំរុំ វៀន តាំ តៀន** «ជុំរុំ ៨៤» ដែលជាតិតាំងអគ សេនាធិការនិងមន្ទីរពេទ្យយោធារបស់វៀតណាម ។ ជំរុំនេះមានផ្ទៃដីស្មើនឹងផ្ទៃដីទីរួមខេត្តបានលុងនៃខេត្តរតនគិរី ។ លោក **យ៉េង ខួង** មានដើម

កំណើតនៅភូមិបានកើត ឃុំតាវែងលើ ស្រុកតាវែង ខេត្តរតនគិរី ។ កាលពីលោកពូមានអាយុ ១៣ ឆ្នាំ លោកពូព្រមទាំងគ្រួសារត្រូវបង្ខំចិត្តរត់ចូលព្រៃ ដែលនៅ ក្បែរជាជំរុំ៨៤ នោះ ។ កាលនោះលោកពូនៅក្មេងអាចដើរដោយសេរីមិនមានអ្នកណាហាមឃាត់ឡើយ ។ តែចំពោះមនុស្សវ័យចំណាស់ដែលអាចដឹងខុសត្រូវគឺគេមិនឲ្យដើរផ្តេផ្តាស់ឡើយ ។ ប៉ុន្តែទោះជាមានបំរាមយ៉ាងតឹងតែងយ៉ាងណាក៏ដោយ ក៏មានពេលខ្លះអ្នកស្រុកចាស់ៗដែលភៀសខ្លួនចូលទៅរស់នៅក្នុងព្រៃនោះបានឃើញកងទ័ពវៀតណាមបណ្តើរទាហានអាមេរិកកាំងដែល ជាប់ខ្នោះ ។

នៅឆ្នាំ ១៩៩៨ មានក្រុមស្វែងរកជនជាតិអាមេរិកកាំងដែលបាត់ខ្លួនក្នុងសង្គ្រាមឥណ្ឌូចិនមួយក្រុម បានទៅធ្វើការស្រាវជ្រាវស្វែងរកអដ្ឋិធាតុទាហានដែលបាត់ខ្លួនក្នុងតំបន់នោះ ។ ពេលនោះ អ្នកដែលធ្លាប់បានឃើញកងទ័ពវៀតណាមបណ្តើរទាហានអាមេរិកក្នុងកំឡុងពេលដែលខ្លួនកំពង់រស់នៅក្នុងព្រៃនៅក្បែរជំរំនោះត្រូវបានជួលឲ្យជួយទៅរកកន្លែងនោះ ។ ប៉ុន្តែការងារ នេះមិនបានសំរេចឡើយដោយគាត់ភ្លេចផ្លូវទៅកាន់ទីនោះ ។

នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ១៩៩៩ លោកពូ **យ៉េន ខ្វន** ដែលជាទាហានស្រុកតាវែង ហើយជាអ្នកដែលធ្លាប់បានរស់នៅក្បែរជំរុំ ៨៤ នោះ រួមដំណើរជាមួយអ្នកស្រុកចំនួន ៦ នាក់ផ្សេងទៀតបានធ្វើការផ្សងព្រេងស្វែងរកកំណប់អដ្ឋិធាតុដែលកប់កាលពី ជាង ៣០ ឆ្នាំមុននោះ ។ ជាលទ្ធផលក្រុមផ្សងព្រេងមួយនេះក៏ទទួលបានជោគជ័យព្រោះបានទៅដល់ទីនោះបន្ទាប់ពីធ្វើដំណើរអស់រយៈពេល ៣ ថ្ងៃមក ។ ជំរុំនោះស្ថិតនៅចំនុចទី ៤៨ អងសាទិសខាងកើតប្រទេសវៀតណាម ។ នៅថ្ងៃដំបូងទី ១៧ក្រុមផ្សងព្រេងនេះ បានធ្វើដំណើរដល់អូរគ្រាងក្រោយពីធ្វើដំណើរតាមកាណូតរួចមក ។ នៅថ្ងៃទី ១៨ ក្រុមនេះបានទៅដល់រហាត់ទឹកដោយថ្មើរជើង ។ នៅថ្ងៃទី ១៩ ក៏ធ្វើដំណើរដល់ចំនុច ៤៨ នៅក្នុងដែនទី ។

ពេលទៅដល់ចំនុចជំរុំ ៨៤ នោះ លោក **យ៉េន ខ្វន** ដែលជាអ្នកផ្តើមគំនិតរុករក បាន ឃើញផ្នូរសាកសពដែលមានដាក់លេខរៀងពី១ ដល់ លេខ ១០០ ហើយក្រៅពីនោះមានផ្នូរដែលមានប្រវែងវែងជាងផ្នូរដែលដាក់លេខរៀងនោះ ។ លោកពូបានបញ្ជាក់ថាផ្នូរកប់ខ្មោចទាំងនោះមានច្រើនរាប់មិនអស់ តែគាត់មានការសង្ស័យទៅលើផ្នូរមួយចំនួនដែលមានប្រវែងវែងជាងផ្នូរធម្មតាហើយគ្មានផ្លាកជាផ្នូរកប់ជនជាតិអាមេរិកកាំងដែលស្លាប់ក្នុងសង្គ្រាម ។ ក្រៅ

ពីផ្លូវខ្មោចនៅមានគ្រាប់សេយោធា,កំប៉ុងថ្នាំពេទ្យដែលមានអក្សរចិន,ចង្ក្រានដាំបាយ, ក្រណាត់កៅស៊ូ,កាំភ្លើងអាទៀរីមួយដើមប្រើការលែងកើត, និងអន្ទាក់ដាក់ សត្វ១ ។

គួរបញ្ជាក់ដែរថាការសង្ស័យរបស់លោក **យ៉េង ខួង** នៅពេលនេះអាចត្រូវជាមួយទិដ្ឋភាពមួយដែលអ្នកភូមិមួយចំនួន បានឃើញទាហានវៀតណាមបណ្តើរជនជាតិអាមេរិកកាំងនោះ ហើយការពិតទាំងនេះ អាចធ្វើឲ្យការស្វែងរកទាហានអាមេរិកកាំងនៅកម្ពុជាជាពិសេសក្នុងខេត្តរតនៈគិរី ទទួលបានជោគជ័យក្នុងករណីដែលមានការប្រឹងប្រែងពុះពារ,ការខបត្តមខាងថវិការ និងសំភារៈបច្ចេកទេស,អ្នកជំនាញការខាងពិនិត្យអដ្ឋិធាតុ និងការសហប្រតិបត្តិការយ៉ាងជិតស្និតជាមួយនឹងរដ្ឋអំណាចមូលដ្ឋាន និងអ្នកស្រុកនៅស្រុកតាវែងនោះ ។

ខ្ញុំមានសុទិដ្ឋិនិយមថាជំរុំមួយដែលត្រូវបានលាក់បាំងជាង២០ឆ្នាំមកនោះ នឹងលាតត្រដាងការពិតនិងរឿងរ៉ាវផ្សេង១ទាក់ទងដល់ការបាត់ខ្លួននៃទាហានអាមេរិកកាំងនៅកម្ពុជា ។ ក្រុមដែនទីរបស់មជ្ឍមណ្ឌលឯកសារកម្ពុជាព្រមទាំងលោក **យ៉េង ខួង** ដែលបានទៅរកឃើញដោយជោគជ័យនូវទីតាំងជំរុំទីតាំងរបស់វៀតណាម និងជាកន្លែងលាក់ខ្លួនរបស់ជនជាតិភាគតិចខ្មែរដែលព្យាយាមភៀសខ្លួនចេញពីការទំលាក់គ្រាប់បែករបស់អាមេរិកកាំងនោះ មានការអនុះសារ និងចង់អោយមានការខិតខំប្រឹងប្រែងមួយដើម្បីស្រាវជ្រាវរក អដ្ឋិធាតុក្នុងគោលបំណងបន្ធូរការឈឺចាប់របស់ក្រុមគ្រួសារនិងញាតិសណ្តានរបស់ទាហានទាំងនោះដែលនៅតែមានអារម្មណ៍វិលវល់គ្មានភាពប្រាកដប្រជាមិនដឹងច្បាស់ថាតើប្តីនិងកូនប្រុសរបស់ខ្លួនស្លាប់ឬក៏នៅរស់រៀនមកដល់ សហស្សវត្សរ៍ថ្មីនាឆ្នាំ ២០០០ នេះ ។